ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ក្រមសីលធម៌

# មន្ត្រីរាជការសវនកម្ម

# នៃអាជ្ញាធរសវនកម្មជាតិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរសវនកម្មជាតិ

លេខ: ០០៣/០១ អសជ.សសវ

# សេចក្ដីសម្រេច

# ស្ដីពី

# ក្រមសីលធម៌

# មន្ត្រីរាជការសវនកម្មនៃអាជ្ញាធរសវនកម្មជាតិ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣០០/១០ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១០០/១១ ចុះថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីច្បាប់បន្ថែមទៅលើច្បាប់ស្ដីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០១/២៥៨ ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០០១ ស្ដីពីការតែង តាំង អគ្គសវនករ អគ្គសវនកររង នៃអាជ្ញាធរសវនកម្មជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០១/២៧១ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០១ ស្ដីពីការតែងតាំងអគ្គលេខាធិការ អគ្គលេខាធិការរងនៃអាជ្ញាធរសវនកម្មជាតិ
- យោងតាមតម្រូវការចាំបាច់របស់អាជ្ញាធរសវនកម្មជាតិ

## គោលការណ៍គ្រឹះនៃក្រមសីលធម៌

ការប្រកាន់ខ្ជាប់វិន័យ និងអាកប្បកិរិយាបានល្អក្នុងការអនុវត្តន៍ការងារ ត្រូវពឹងផ្អែកទៅលើគោលការណ៍គ្រឹះមួយចំនួនដែលគេចាត់ទុកថាជាលក្ខណសម្បត្តិនៃវិជ្ជាជីវៈសវនកម្ម ។ គោលការណ៍គ្រឹះនេះ ជាយានដឹកនាំសវនករឆ្ពោះទៅរកការទទួលខុសត្រូវមុខវិជ្ជាជីវៈរបស់ខ្លួន និងជាគ្រឹះនៃក្រមសីលធម៌ក្នុងការបំពេញកាតព្វកិច្ចរបស់សវនករ ។

គោលការណ៍គ្រឹះទាំងនោះគឺ :

### ភាពសុចរិត

សវនករត្រូវប្រកាន់ភាពទៀងត្រង់ សុចរិត និងស្មោះស្ម័គ្រ នៅក្នុងការអនុវត្តន៍ការងាររបស់ខ្លួន ។

### សត្យានុម័ត

សវនករត្រូវប្រកាន់ខ្ជាប់នូវភាពមិនលំអៀង ទៀងត្រង់ និងជៀសវាងនូវទំនាស់ផលប្រយោជន៍ ។សវនករត្រូវប្រកាន់ខ្ជាប់នូវភាពត្រឹមត្រូវ និងមិនអនុញ្ញាតឱ្យប៉ះពាល់ ឬលំអៀងដល់សត្យានុម័តរបស់ខ្លួន ។

### សមត្ថកិច្ចវិជ្ជាជីវៈ

សវនករត្រូវមានជំនាញកំរិតខ្ពស់ក្នុងការប្រកបមុខវិជ្ជាជីវៈរបស់ខ្លួន។ សវនករត្រូវបំពេញតែភារកិច្ចណាដែលស្ថិតនៅក្នុងសមត្ថកិច្ចវិជ្ជាជីវៈរបស់ខ្លួន ។

### ស្តង់ដារបច្ចេកទេស

សវនករត្រូវបំពេញភារកិច្ចរបស់ខ្លួនដោយប្រើប្រាស់ស្តង់ដារបច្ចេកទេសនិងវិជ្ជាជីវៈស្របទៅតាមការងារដែលខ្លួនកំពុងអនុវត្ត ។

### អាកប្បកិរិយាក្នុងវិជ្ជាជីវៈ

សវនករត្រូវប្រកាន់ខ្ជាប់នូវអាកប្បកិរិយាសមស្របនឹងភាពថ្លៃថ្នូរនៃវិជ្ជាជីវៈ ហើយជៀសវាងនូវរាល់ទង្វើណាដែលនាំឱ្យអាប់ឱនដល់វិជ្ជាជីវៈរបស់ខ្លួន។

### ការសម្ងាត់វិជ្ជាជីវៈ

សវនករត្រូវប្រកាន់ខ្ជាប់នូវការសម្ងាត់វិជ្ជាជីវៈ និងមិនត្រូវផ្សព្វផ្សាយពត៌មានទាំងនោះទៅបុគ្គលទីបី ដោយពុំមានការអនុញ្ញាតិពីអគ្គសវនករ លើកលែងតែការផ្តល់ពត៌មាននោះជាការអនុវត្តន៍ភារកិច្ចរបស់ខ្លួន។

### ឯករាជ្យភាព

ឯករាជ្យភាពក្នុងន័យដែលថា ខ្លួនទីពឹងខ្លួននឹងមិនស្ថិតក្រោមបញ្ជាពីខាងក្រៅជាកត្តាចាំបាច់នៅក្នុងការអនុវត្តន៏វិជ្ជាជីវៈ។ នៅរាល់លំដាប់ការងារ សវនករត្រូវតែស្ថិតនៅក្នុងភាពឯករាជ្យ ដើម្បីបំពេញភារកិច្ចបានត្រឹមត្រូវ។

## ជំពូកទី ១
## ទស្សនទាន បរិបទ និងគោលបំណងនៃក្រមសីលធម៌

១. អាកប្បកិរិយារបស់សវនករ ត្រូវមានភាពត្រឹមត្រូវគ្រប់ពេលវេលា និងគ្រប់កាលៈទេសៈទាំងអស់។ រាល់ភាពខ្វះខាតក្នុងការបំពេញកាតព្វកិច្ចវិជ្ជាជីវៈដែលខ្លួនតំណាងឱ្យអាជ្ញាធរ ឬអំពើប្រាសចាកសីលធម៌ណាមួយ ក្នុងជីវិតឯកជននឹងនាំទៅដល់ការវាយតម្លៃទាបលើភាពសុចរិតលើ គុណភាព និងលើសុពលភាព នៃការងារសវនកម្ម និងនាំឱ្យកើតមានការសង្ស័យមិនទុកចិត្តទៅលើ សមត្ថកិច្ចរបស់

អាជ្ញាធរសវនកម្មជាតិទៀតផង។ ការទទួលយក និងការអនុវត្តន៍ក្រមសីលធម៌ នឹងបង្កើន នូវជំនឿទុកចិត្តចំពោះការងាររបស់ សវនករ និងសវនករផ្ទាល់ ។

២. កត្តាដ៏សំខាន់បំផុត គឺត្រូវធ្វើយ៉ាងណាអោយសាធារណជនមានជំនឿទំនុកចិត្ត និងផ្តល់កិត្តិនាមឱ្យអាជ្ញាធរសវនកម្មជាតិ។ សវនករត្រូវលើកកំពស់បញ្ហានេះតាមរយៈការទទួលយក និងការអនុវត្តន៍តាម លក្ខខណ្ឌដែលក្រមសីលធម៌តម្រូវ តាមទស្សនទានដែលមានពាក្យគន្លឹះ ដូចជា ភាពសុចរិត ឯករាជ្យ សត្យានុម័ត រក្សាការសម្ងាត់ និងសមត្ថភាព ។

## ជំនឿ ទំនុកចិត្ត និងកិត្តិនាម

៣. ស្ថាប័ននីតិបញ្ញត្តិ ឬ/និង ស្ថាប័ននីតិប្រតិបត្តិ សាធារណជន ព្រមទាំងស្ថាប័នដែលរងសវនកម្មមានសិទ្ធិរំពឹងនឹង ទទួលបានពីអាជ្ញាធរសវនកម្មជាតិ នូវរបៀបរបបការងារ និងវិធីសាស្ត្រដែលគ្មានមន្ទិលសង្ស័យ និងគ្មាន ការទិតៀនព្រមទាំងមានការគោរព និងការទុកចិត្តបាន។

៤. សវនករត្រូវធ្វើយ៉ាងណាឱ្យមានកិច្ចសហការ និងទំនាក់ទំនងល្អ រវាងសវនករ និង សវនករ ព្រមទាំងក្នុងវិជ្ជាជីវៈ។ ការគាំទ្រវិជ្ជាជីវៈដោយសមាជិក និងកិច្ចសហការគ្នាទៅវិញទៅមក គឺជាធាតុផ្សំចាំបាច់នៃវិជ្ជាជីវៈសវនកម្ម ។ ទំនុកចិត្ត និងការគោរពពីសាធារណជនចំពោះសវនករ គឺជាលទ្ធផលនៃការងារជាបន្តបន្ទាប់របស់សវនករទាំង អស់ទាំងក្នុងអតីតកាល និងបច្ចុប្បន្នកាល ។ ដូច្នេះដើម្បីជាផលប្រយោជន៍របស់សវនករ ព្រមទាំងផល ប្រយោជន៍ របស់សាធារណៈជន សវនករត្រូវធ្វើការជាមួយសវនកររួមការងារតាមគោលការណ៍ត្រឹមត្រូវ និងមានតុល្យភាព ។

៥. ស្ថាប័ននីតិបញ្ញត្តិឬ/និងស្ថាប័ននីតិប្រតិបត្តិ សាធារណជន និងស្ថាប័នដែលរងសវនកម្ម គប្បីត្រូវទទួលបានការ ធានានូវភាពត្រឹមត្រូវ និងមិនលំអៀងពីគ្រប់ការងាររបស់អាជ្ញាធរសវនកម្មជាតិ ។ ដូចនេះចាំបាច់អាជ្ញាធរសវនកម្មជាតិត្រូវមានក្រមសីលធម៌។

៦. អាជ្ញាធរសវនកម្មជាតិ ត្រូវធ្វើយ៉ាងណាឱ្យមានជំនឿទុកចិត្តពីគ្រប់ស្រទាប់នៃសង្គម។ ដូច្នេះជាចាំបាច់របាយការណ៍ និងមតិយោបល់របស់អាជ្ញាធរសវនកម្មជាតិ ត្រូវបានចាត់ទុកថាត្រឹមត្រូវយ៉ាងពិតប្រាកដ និងគួរទុកចិត្តបានពីភាគីទីបីដែលមានការយល់ដឹង ។

៧. ការងារទាំងអស់ដែលអាជ្ញាធរសវនកម្មជាតិបានអនុវត្តន៍ ត្រូវតែប្រឈមនឹងការសាកសួរ ពីស្ថាប័ននីតិ បញ្ញត្តិ ឬ/និង ស្ថាប័ននីតិប្រតិបត្តិ ព្រមទាំងការវិនិច្ឆ័យរបស់សាធារណជនលើភាពត្រឹមត្រូវ និងគោរពតាមក្រមសីលធម៌ជាតិ។

## ជំពូកទី ២
## ភាពសុចរិត

៨. ភាពសុចរិតគឺជាតម្លៃមូលដ្ឋាននៃក្រមសីលធម៌ ។ សវនករទាំងអស់មានករណីយកិច្ចគោរពតាមនិយាមសីលធម៌ (ដូចជា មានភាពស្មោះត្រង់ និងភាពស្មោះស្ម័គ្រ) ក្នុងពេលបំពេញការងារក៏ដូចជាក្នុង ទំនាក់ទំនង

ជាមួយបុគ្គលិក នៃស្ថាប័ន ដែលរងសវនកម្ម ។ ដើម្បីរក្សាបាននូវទំនុកចិត្តពីសាធារណជន អាកប្បកិរិយារបស់សវនករត្រូវជៀសឱ្យផុតពីការសង្ស័យ និងការទិតៀន ។

៩. ភាពសុចរិតអាចវាស់បានទៅតាមភាពត្រឹមត្រូវ និងសមធម៌ ។ ភាពសុចរិតតម្រូវឱ្យសវនករ គោរពតាមទ្រង់ទ្រាយខ្លឹមសារនៃសវនកម្ម និងក្រមសីលធម៌។ ភាពសុចរិតក៏តម្រូវឱ្យសវនករគោរពតាម គោលការណ៍ស្តីពីឯករាជ្យភាព និងសត្យានុម័ត ហើយរក្សាបាននូវអាកប្បកិរិយាវិជ្ជាជីវៈត្រឹមត្រូវធ្វើ សេចក្តីសំរេចដោយឈរលើផលប្រយោជន៍សាធារណៈ និងបង្ហាញភាពស្មោះត្រង់ដាច់ខាតក្នុងពេលអនុវត្តការងារក៏ដូចជាការប្រើប្រាស់ធនធានរបស់អាជ្ញាធរសវនកម្មជាតិ។

## ជំពូកទី ៣
## ឯករាជ្យភាព សត្យានុម័ត និងភាពមិនលំអៀង

១០. ភាពឯករាជ្យមិនចំណុះស្ថាប័នដែលរងសវនកម្ម និងអ្នកខាងក្រៅដែលមានផលប្រយោជន៍ គឺជាកត្តាចាំបាច់បំផុតសំរាប់សវនករ ។ បញ្ហានេះតម្រូវឱ្យសវនករត្រូវធ្វើតាមគ្រប់មធ្យោបាយដើម្បីលើកកំពស់ ឯករាជ្យភាព និងមិនត្រូវធ្វើអ្វីដែលនាំឱ្យធ្លាក់ចុះនូវឯករាជ្យភាពឡើយ ។

១១. សវនករមិនត្រឹមតែត្រូវពុះពារឱ្យមានឯករាជ្យពីស្ថាប័នដែលរងសវនកម្ម និងក្រុមអ្នកដែលមានផលប្រយោជន៍ប៉ុណ្ណោះទេ ប៉ុន្តែត្រូវប្រកាន់ជំហរសត្យានុម័តក្នុងការដោះស្រាយការងារ និងបញ្ហាទាំងឡាយដែលខ្លួនត្រូវពិនិត្យ ។

១២. ប្រការចាំបាច់សវនករមិនត្រឹមតែរក្សានូវឯករាជ្យ និងភាពមិនលំអៀងក្នុងការងារប៉ុណ្ណោះទេ ប៉ុន្តែត្រូវស្តែងចេញតាមអាកប្បកិរិយាខាងក្រៅទៀតផង។

១៣. រាល់បញ្ហាទាំងឡាយដែលទាក់ទិននឹងការងារសវនកម្ម ឯករាជ្យភាពរបស់សវនករមិនត្រូវឱ្យខូចខាតដោយសារផលប្រយោជន៍បុគ្គល ឬផលប្រយោជន៍ពីខាងក្រៅឡើយ ។ ជាឧទាហរណ៍ ឯករាជ្យភាពអាច នឹងត្រូវខូចខាត ដោយសារសម្ពាធ ឬឥទ្ធិពលពីខាងក្រៅលើសវនករ ដោយសារបុរេវិនិច្ឆ័យរបស់សវនករ លើបុគ្គល ស្ថាប័ន គំរោង ឬកម្មវិធីដែលរងសវនកម្ម ដោយសារការងារទើបបញ្ចប់ថ្មីៗជាមួយស្ថាប័នដែលរងសវនកម្មដោយ សារ ទំនាក់ទំនងផ្ទាល់ខ្លួន ឬហិរញ្ញវត្ថុ ដែលអាចជាប្រភពនាំដល់ការកើតទំនាស់ផលប្រយោជន៍ ឬទំនាស់ពី ភាពស្មោះត្រង់ ។ សវនករមានកាតព្វកិច្ចដកខ្លួនចេញពីបញ្ហាទាំងឡាយដែលខ្លួនមានផលប្រយោជន៍លេច ធ្លោនៅក្នុងនោះ។

១៤. ជាការចាំបាច់ត្រូវមានសត្យានុម័ត និងភាពមិនលំអៀង ក្នុងការងារទាំងអស់របស់សវនករ ជាពិសេសក្នុងរបាយការណ៍សវនកម្មដែលត្រូវតែត្រឹមត្រូវ និងសត្យានុម័ត ។ ដូច្នេះសេចក្តីសន្និដ្ឋានលើយោបល់ និងរបាយការណ៍ត្រូវ ផ្អែកតែលើភស្តុតាងដែលទទួលបាន និងប្រមូលបានស្របតាមស្តង់ដារសវនកម្មរបស់អាជ្ញាធរសវនកម្មជាតិ ។

១៥. សវនករគប្បីប្រើប្រាស់ពត៌មានបានមកពីស្ថាបន័ដែលរងសវនម្ម និងប្រភពពត៌មានផ្សេងទៀត ។ នៅក្នុងមតិរបស់ខ្លួន សវនករ ត្រូវតែប្រកាន់នូវគោលការណ៍មិនលំអៀងចំពោះរាល់ពត៌មានដែលខ្លួនបានទទួល ។ ជាមួយ

នេះ សវនករត្រូវប្រមូលមតិផ្សេងៗទៅលើស្ថាប័នដែលរងសវនកម្ម និងស្ថាប័នដទៃទៀត ។ ក៏ប៉ុន្តែយោបល់ផ្ទាល់របស់ សវនករ ពុំត្រូវទទួលឥទ្ធិពលពីមតិផ្សេងៗនោះជាដាច់ខាត ។

## អព្យាក្រឹតភាពខាងនយោបាយ

១៦. ការរក្សាអព្យាក្រឹតភាពខាងនយោបាយក្នុងការងារនិងទស្សនៈ ជាប្រការដ៏សំខាន់របស់អាជ្ញាធរសវនកម្មជាតិ ។ ដូច្នេះបញ្ហាសំខាន់ សវនករត្រូវរក្សាឯករាជ្យភាពពីឥទ្ធិពលនយោបាយដើម្បីបំពេញភារកិច្ចទទួលខុសត្រូវក្នុងការធ្វើសវនកម្ម ដោយមិនលំអៀង ។ ដើម្បីធ្វើទៅបានលុះត្រាតែអាជ្ញាធរសវនកម្មជាតិ សហការយ៉ាងជិតស្និទ្ធជាមួយស្ថាប័ននីតិបញ្ញត្តិនីតិប្រតិបត្តិដែលច្បាប់អនុញ្ញាតឱ្យពិនិត្យនូវរបាយការណ៍របស់ អាជ្ញាធរសវនកម្មជាតិ ។

១៧. ជាការសំខាន់នៅពេលដែលសវនករចូលរួម ឬមានបំណងចូលរួមបំរើសកម្មភាពនយោបាយនោះ ជាចាំបាច់គេត្រូវគិតពីការប៉ះទង្គិចដែលអាចមាន ឬនឹងអាចមានទៅលើសមត្ថភាពរបស់ខ្លួនក្នុងការបំពេញវិជ្ជាជីវៈសវនកម្មដោយមិនលំអៀង ។ បើសិនជាសវនករត្រូវបានអនុញ្ញាតអោយចូលបំរើនយោបាយនោះ គេត្រូវមានមនសិការថា សកម្មភាពនយោបាយអាចនាំឱ្យប៉ះទង្គិចដល់មុខវិជ្ជាជីវៈសវនកម្ម ។

## ទំនាស់ផលប្រយោជន៍

១៨. នៅពេលដែលសវនករ ត្រូវបានអនុញ្ញាតឱ្យផ្តល់ការណែនាំ ឬផ្តល់សេវាដទៃទៀតក្រៅពីសវនកម្មទៅស្ថាប័នដែលរងសវនកម្មនោះ សវនករត្រូវតែយល់ថាសេវាទាំងនោះពុំបណ្តាលអោយមានទំនាស់ផលប្រយោជន៍ទេ ។ ជាពិសេស សវនករត្រូវតែយល់ថាការផ្តល់ការណែនាំ ឬការផ្តល់សេវារបស់ខ្លួនពុំមានបញ្ចូលនូវការទទួលខុសត្រូវ ឬបុព្វសិទ្ធិរដ្ឋបាលណាមួយឡើយ ព្រោះថាប្រការនោះនៅតែជា ភារកិច្ចរបស់ស្ថាប័នដែលរងសវនកម្ម ។

១៩. សវនករត្រូវការពារឯករាជ្យភាពរបស់ខ្លួន និងជៀសចេញពីរាល់ទំនាស់ផលប្រយោជន៍ដោយពុំទទួលយកអំណោយ ឬ សគុណដែលអាចជះឥទ្ធិពល ឬត្រូវបានគិតថានឹងជះឥទ្ធិពលទៅលើឯករាជ្យភាព និងសុចរិតភាពរបស់ខ្លួន។

២០. សវនករត្រូវជៀសវាងរាល់ទំនាក់ទំនងជាមួយអ្នកទទួលខុសត្រូវ និងបុគ្គលិកនៃស្ថាបន័ដែលរងសវនកម្ម និងអ្នកដទៃទៀត ដែលអាចជះឥទ្ធិពលធ្វើអោយប៉ះពាល់ ឬធ្វើឱ្យខូច ឬគំរាមកំហែងដល់សមត្ថភាពរបស់សវនករ ក្នុងការបំពេញភារកិច្ចរបស់ខ្លួនដោយឯករាជ្យ។

២១. សវនករ មិនត្រូវឆ្លៀតយកមុខដំណែងផ្លូវការរបស់ខ្លួន ដើម្បីទាញយកផលប្រយោជន៍ផ្ទាល់ខ្លួន និងត្រូវជៀសវាង នូវទំនាក់ទមនងណាដែលអាចនាំមកនូវគ្រោះនៃអំពើពុករលួយ ឬធ្វើអោយមានការសង្ស័យដល់ភាពសត្យានុម័ត និងឯករាជ្យភាពរបស់ខ្លួន ។

២២. សវនករ មិនត្រូវយកពតិមានដែលទទួលបានក្នុងការងារ ដើម្បីទាញយកផលប្រយោជន៍ផ្ទាល់ខ្លួន ឬសំរាប់អ្នកដទៃឡើយ។ ជាមួយគ្នានោះ សវនករមិនត្រូវប្រើប្រាស់ពតិមានសម្ងាត់ដែលធ្វើឱ្យបុគ្គល ឬអង្គភាព ទទួលផល

ដោយមិនត្រឹមត្រូវ ឬមិនសមហេតុសមផល ក៏ដូចជាមិនត្រូវប្រើប្រាស់ពត៌មានទាំងនោះ ដើម្បីធ្វើឱ្យអន្តរាយដល់អ្នកដទៃឡើយ ។

## ជំពូកទី ៤
## ការសម្ងាត់វិជ្ជាជីវៈ

២៣. សវនករមិនត្រូវប្រើប្រាស់ពត៌មានសម្ងាត់ដែលបានពីការធ្វើសវនកម្មទៅអោយភាគីទីបី ទោះតាមការនិយាយ ឬតាមការសរសេរក៏ដោយ លើកលែងតែក្នុងករណីដែល ច្បាប់ស្ដីពីសវនកម្ម នៃព្រះរាជាណាចក្រកម្ពុជា បទបញ្ញា ផ្សេងៗរបស់អាជ្ញាធរសវនកម្មជាតិ ឬច្បាប់ជាធរមានផ្សេងទៀតអនុញ្ញាត ។

## ជំពូកទី ៥
## សមត្ថកិច្ច

២៤. សវនករមានភារកិច្ចត្រូវប្រកាន់ខ្ជាប់គ្រប់ពេលវេលា នូវសីលធម៌វិជ្ជាជីវៈ និងអនុវត្តដោយហ្មត់ចត់នូវស្តង់ដារវិជ្ជាជីវៈក្នុងការបំពេញភារកិច្ចរបស់ ខ្លួនអោយអស់ពីសមត្ថភាព និងភាពមិនលំអៀង ។

២៥. សវនករមិនត្រូវបំពេញសកម្មភាពអ្វីមួយ ដែលខ្លួនពុំមានសមត្ថភាពបំពេញនោះឡើយ ។

២៦. សវនករត្រូវចេះដឹង និងអនុវត្តនូវស្តង់ដារ គោលការណ៍ និងនីតិវិធីសវនកម្ម នីតិវិធីគណនេយ្យ និងនីតិវិធីនៃការគ្រប់គ្រងហិរញ្ញវត្ថុដែលអាចអនុវត្តបាន ។ ជាមួយនោះ សវនករត្រូវតែក្តាប់អោយបានច្បាស់នូវគោលការណ៍ រដ្ឋធម្មនុញ្ញ ច្បាប់ ស្ថាប័ន និង ស្តង់ដារគ្រប់គ្រងដំណើរការរបស់អង្គភាពដែលរងសវនកម្ម ។

## ការអភិវឌ្ឍន៍វិជ្ជាជីវៈ

២៧. សវនករត្រូវប្រកាន់ខ្ជាប់នូវមុខវិជ្ជាជីវៈរបស់ខ្លួនក្នុងការដឹកនាំ និងការត្រួតពិនិត្យសវនកម្ម ព្រមទាំងការរៀបចំរបាយការណ៍ពាក់ព័ន្ធ ។

២៨. សវនករត្រូវប្រើប្រាស់វិធី និងការអនុវត្តន៍នូវគុណភាពសវនកម្មកំរិតខ្ពស់បំផុតដែលអាចធ្វើទៅបាន ។ ក្នុងការធ្វើសវនកម្ម ឬសរសេររបាយការណ៍ សវនករត្រូវគោរពនូវគោលការណ៍គ្រឹះ និងស្តង់ដារសវនកម្ម ដែលបានទទួលស្គាល់ ។

២៩. សវនករត្រូវបង្កើនចំណេះដឹង និងសមត្ថភាពរបស់ខ្លួនជារៀងរហូត ដែលជាតម្រូវការចាំបាច់សំរាប់បំពេញមុខងារប្រកបដោយការទទួលខុសត្រូវខាងវិជ្ជាជីវៈ ។

៣០. ប្រព័ន្ធនៃការលើកទឹកចិត្តនិងផ្តល់រង្វាន់ ត្រូវបានបង្កើតឡើងដើម្បីលើកទឹកចិត្ត និងគាំទ្រស្មារតីរបស់មន្ត្រីសវនកម្ម ក្នុងការលើកតំកើងក្រមសីលធម៌ឱ្យបានកំរិតមួយខ្ពស់បំផុត ។

៣១. មន្ត្រីរាជការសវនកម្មណាក៏ដោយ ដែលប្រព្រឹត្តបំពាននឹងក្រមសីលធម៌នេះ នឹងត្រូវទទួលរងទណ្ឌកម្មតាមច្បាប់ ស្តីពីសហលក្ខន្តិកៈនៃមន្ត្រីរាជការស៊ីវិល ច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា និងបទប្បញ្ញត្តិនានា របស់អាជ្ញាធរសវនកម្មជាតិ ។

# អនុសាសន៍របស់អគ្គសវនករ

ក្នុងឋានៈជាបុគ្គលិកនៃវិជ្ជាជីវៈនេះ យើងមានកាតព្វកិច្ចត្រូវប្រកាន់ខ្ជាប់នូវអាកប្បកិរិយា និងឥរិយាបថអោយបានត្រឹមត្រូវចំពោះការទួលខុសត្រូវរបស់យើង លើស្ថាប័នដែលរងសវនកម្ម និងចំពោះអ្នកដែលធ្វើការជាមួយយើង ។

កាតព្វកិច្ចត្រូវស្ថិតនៅជាមួយយើង ព្រោះយើងបានជ្រើសរើសមុខវិជ្ជាជីវៈមួយដែលមានលក្ខណៈទទួលខុសត្រូវ និងការទុកចិត្តខ្ពស់ ។

ទាំងអស់នេះជាគុណភាពដែលយើងឱ្យតម្លៃ ។ ចំណេះដឹងផ្នែកជំនាញរបស់យើង មិនធានាអនុវត្តដោយជោគជ័យនូវការងារសវនកម្មបានទេ ប្រសិនបើគ្មានការគោរពយ៉ាងម៉ឺងម៉ាត់នូវក្រមសីលធម៌ដូចមានចែងមកនេះទេ។

ក្រមសីលធម៌នេះ ជាផ្នែកមួយនៃការអនុវត្តនៃវិជ្ជាជីវៈហើយដែលសវនករទាំងអស់ត្រូវប្រតិបត្តិតាមគ្រប់ពេលវេលា ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០០២

**អគ្គសវនករ**

**អ៊ុត ឈន**